**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ : ០០១ សណន

**សេចក្តីណែនាំ**
**ស្តីពី**
**ការអនុញ្ញាតច្បាប់ឈប់សម្រាកពីការងាររបស់មន្ត្រីនគរបាលជាតិ**

យោងតាមព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា និង វិន័យរបស់កងកម្លាំងនគរបាលជាតិ លេខ០០៦ បបជ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ក្នុងគោលបំណងធ្វើកំណែទម្រង់និងពង្រឹងអភិបាលកិច្ចល្អក្នុងការជំរុញឱ្យមន្ត្រីនគរបាលជាតិ គោរពវិន័យការងារបានត្រឹមត្រូវ ធានានិរន្តរភាព និងលើកកម្ពស់ប្រសិទ្ធភាពការងារ ព្រមទាំងផ្តល់សុខុមាលភាពដល់មន្ត្រីនគរបាលជាតិ ក្រសួងមហាផ្ទៃសូមធ្វើការណែនាំស្តីពីការអនុញ្ញាតច្បាប់ឈប់សម្រាកពីការងាររបស់មន្ត្រីនគរបាលជាតិ ដូចតទៅៈ

១- រដ្ឋមន្ត្រីសម្រេចអនុញ្ញាតច្បាប់ឈប់សម្រាកគ្រប់ប្រភេទជូន អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋាននានា ប្រធានអង្គភាពថ្នាក់ប្រហាក់ប្រហែល ចំណុះក្រសួងមហាផ្ទៃ។

២- រដ្ឋមន្ត្រីប្រគល់សិទ្ធិក្នុងការអនុញ្ញាតច្បាប់ ដូចខាងក្រោមៈ

- អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋាននានា និងប្រធានអង្គភាពថ្នាក់ប្រហាក់ប្រហែលចំណុះក្រសួងមហាផ្ទៃ មានសិទ្ធិសម្រេចអនុញ្ញាតច្បាប់ឈប់សម្រាក រយៈពេលត្រឹម៥(ប្រាំ)ថ្ងៃចុះ។

- ប្រធាននាយកដ្ឋាន ប្រធានអង្គភាព ចំណុះអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋាននានា ប្រធានអង្គភាពថ្នាក់ប្រហាក់ប្រហែល និងស្នងការនៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត មានសិទ្ធិសម្រេចអនុញ្ញាតច្បាប់ឈប់សម្រាកជូនមន្ត្រីនគរបាលក្រោមឱវាទ រយៈពេលត្រឹម៣(បី)ថ្ងៃចុះ។

- នាយកសាលានគរបាលជាតិមិត្តភាពកម្ពុជា-វៀតណាម នាយកសាលានគរបាលជាតិភូមិភាគ អធិការនៃអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោក-ទឹក ប្រធានអង្គភាពបង្ក្រាបបទល្មើសលើផ្ទៃសមុទ្រ នាយកសាលាហ្វឹកហ្វឺនជំនាញនគរបាលការពារព្រំដែន ប្រធានស្នាក់ការប្រឆាំងចារកម្មរាជធានី ខេត្ត នៃនាយកដ្ឋានចារកម្ម ប្រធានស្នាក់ការប្រចាំតំបន់ នៃនាយកដ្ឋានប្រឆាំងបទល្មើសល្បែងពាណិជ្ជកម្ម ប្រធានអង្គភាពនគរបាលទេសចរណ៍ ប្រធានអង្គភាពនគរបាលការពារបេតិកភណ្ឌ ប្រធានសាខាលិខិតឆ្លងដែនប្រចាំតំបន់ នាយប៉ុស្តិ៍នគរបាលច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ នាយប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិ និងនាយប៉ុស្តិ៍នគរបាលច្រកទ្វារកំពង់ផែអន្តរជាតិ មានសិទ្ធិសម្រេចអនុញ្ញាតច្បាប់ឈប់សម្រាកជូនមន្ត្រីនគរបាលក្រោមឱវាទ រយៈពេលត្រឹម២(ពីរ)ថ្ងៃចុះ។

- នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ មានសិទ្ធិសម្រេចអនុញ្ញាតច្បាប់ឈប់សម្រាកជូនមន្ត្រីនគរបាលក្រោមឱវាទ រយៈពេលត្រឹម១(មួយ)ថ្ងៃ។

៣- មន្ត្រីនគរបាលជាតិ ដែលសុំច្បាប់ឈប់សម្រាកចាប់ពីរយៈពេល៦(ប្រាំមួយ)ថ្ងៃ ដល់១០(ដប់)ថ្ងៃ និងការសុំច្បាប់លំហែមាតុភាព ត្រូវមានការសម្រេចពីរដ្ឋលេខាធិការទទួលបន្ទុកអគ្គនាយកដ្ឋានធនធានមនុស្ស។ ក្នុងករណីសុំច្បាប់ឈប់សម្រាកលើសពីរយៈពេល១០(ដប់)ថ្ងៃ ត្រូវសុំការសម្រេចពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

៤- មន្ត្រីនគរបាលជាតិ ដែលសុំច្បាប់ឈប់សម្រាកដូចបានកំណត់ខាងលើ ត្រូវធ្វើពាក្យស្នើសុំជាលាយល័ក្ខអក្សរតាមឋានានុក្រម ដោយភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់ផ្សេងៗ។

៥- ប្រធានអង្គភាពនីមួយៗ ត្រូវរៀបចំបញ្ជីឈប់សម្រាកពីការងាររបស់មន្ត្រីនគរបាលចំណុះអង្គភាពឱ្យបានសមស្រប ដើម្បីធានានិរន្តរភាពការងាររបស់អង្គភាពប្រព្រឹត្តទៅជាធម្មតា។

ទទួលបានសេចក្តីណែនាំនេះ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានមនុស្ស អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានកស្តុភារ និងហិរញ្ញវត្ថុ ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថលនិងផ្សព្វផ្សាយអប់រំ ប្រធានក្រុមប្រឹក្សានីតិកម្ម ប្រធានអង្គភាពពាក់ព័ន្ធ និងស្នងការនៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ត្រូវចាត់ចែងផ្សព្វផ្សាយ និងអនុវត្តឱ្យមានប្រសិទ្ធភាពប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។៙

ថ្ងៃ សុក្រ ១រោច ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមអភិសន្តិបណ្ឌិត
- ឯកសារ កាលប្បវត្តិ